# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៩៣ អបស.ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៥

# ប្រកាស
## ស្តីពី
## ការកែសំរួលប្រកាសលេខ ១០៣១ អបស/ឱអបស ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់ក្រសួងសុខាភិបាល ស្តីពីបែបបទ អាហារ័ណ-នីហារ័ណកម្មឱសថ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ កញ្ញា ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២ តុលា១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ ប្រកាសលេខ ១០៣១ អបស/ឱអបស ចុះថ្ងៃទី០៣ វិច្ឆិកា ២០០៨ ស្តីពីការកែសម្រួលប្រកាសលេខ ៨២ អបស/ឱអបស ចុះថ្ងៃទី៣១ មីនា ១៩៩៩ស្តីពីបែបបទ អាហារ័ណ នីហារ័ណកម្មឱសថ

-និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## សម្រេច

**ប្រការ១ ៖** ខ្លឹមសារប្រកាសលេខ ១០៣១ អបស/ឱអបស ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ក្រសួងសុខាភិបាលត្រូវបានកែសំរួលដូចខាងក្រោម ។

**ប្រការ២ ៖** អាហារ័ណ នីហារ័ណកម្ម សំរាប់ធ្វើពាណិជ្ជកម្មឱសថ ផលិតកម្មឱសថ ជាភារកិច្ចរបស់គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ និងគ្រឹះស្ថានផលិតឱសថ ដែលមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ៣ ៖** ការនាំចូល ឬនាំចេញនូវៈ

-ឱសថគ្រប់ប្រភេទសំរាប់វិស័យសុខាភិបាល

-ផលិតផលអនាម័យ ផលិតផលគ្រឿងសំអាង ផលិតផលឱសថបុរាណ ផលិតផលឱសថ ផលិតផលឌីយ៉េតេទិក ដែលមានគុណភាព ក្នុងការបង្ការ ឬព្យាបាលជំងឺ ឬអនាម័យខ្លួនប្រាណមនុស្ស

-សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ

-សម្ភារៈប្រតិករសំរាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ

-សារធាតុសកម្ម សារធាតុផ្សំ សម្ភារៈវេចខ្ចប់បំរើឲ្យផលិតកម្មឱសថសំរាប់គ្រឹះស្ថានផលិតឱសថអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ៤ ៖** បែបបទនាំចូលឱសថត្រូវមានៈ

-ពាក្យសុំនាំចូលឱសថ( មានគំរូ ) ដោយភ្ជាប់មកជាមួយនូវៈ

១-Airway Bill ឬBill of lading ឬTruck Bill (Scanned Original Copy និង Email ទាំង Address របស់អ្នកផ្ញើ និងអ្នកទទួល) ចំនួន ០៣ ច្បាប់

២-Commercial Invoice (Scanned Original Copy និង Email ទាំង Address របស់អ្នកផ្ញើ និងអ្នកទទួល) ចំនួន ០៣ ច្បាប់

៣-Packing List (Scanned Original Copy និង Email ទាំង Address របស់អ្នកផ្ញើ និងអ្នកទទួល) ចំនួន ០៣ ច្បាប់

៤-តារាងលេខបញ្ជិកាឱសថនាំចូល (ច្បាប់ដើម) ចំនួន ០៣ ច្បាប់

-លិខិតអនុញ្ញាតនាំចូលឱសថរបស់ក្រសួងសុខាភិបាលមានសុពលភាពរយៈពេល ០១ខែ ។

**ប្រការ៥ ៖** ឱសថដែលអនុញ្ញាតឲ្យនាំចូលមកតាំងលក់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខបញ្ជិកាយល់ព្រមពីក្រសួងសុខាភិបាល។ ឱសថដែលនាំចូលត្រូវមានសុពលភាពប្រើយ៉ាងតិច ១៨ខែ នៅពេលមកដល់ព្រះរាជាណាចក្រកម្ពុជា។ ចំពោះឱសថ-ឱសថបង្ការ( សេរ៉ូម-វ៉ាក់សាំង ) និងប្រតិករដែលមានរយៈពេលប្រើទាបជាង ១៨ខែ ត្រូវមានសុពលភាពប្រើយ៉ាងតិច ២/៣ នៃរយៈពេលប្រើប្រាស់ នៅពេលមកដល់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៦ ៖** ឱសថនាំចូលត្រូវមានទម្រង់បង្ហាញត្រឹមត្រូវតាមឱសថគំរូ ដែលមានលេខបញ្ជិកាយល់ព្រមពីក្រសួងសុខាភិបាល និងមានគុណភាពត្រឹមត្រូវតាមព្រឹត្តប័ត្រវិភាគគុណភាព (Analysis Certificate of Exported batch) ដែលត្រូវរក្សាទុកសំរាប់ការត្រួតពិនិត្យរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ នៃក្រសួងសុខាភិបាល ។

**ប្រការ៧ ៖** ផលិតផលឱសថអាចស្តុកបានតែក្នុងឃ្លាំងឱសថ ដែលមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ៨ ៖** ឱសថនាំចូលតាមកញ្ចប់ប្រៃសណីយ៍ ដែលមានទម្ងន់លើសពី ៣គីឡូក្រាម ត្រូវអនុវត្តតាមប្រកាសនេះ។

**ប្រការ៩ ៖** បែបបទនាំចេញឱសថត្រូវមានៈ

-ពាក្យសុំនាំចេញឱសថ(មានគំរូ) ដោយភ្ជាប់មកជាមួយនូវៈ

១-Commercial Invoice Original ០១ ច្បាប់+ថតចម្លង ០២ ច្បាប់

២-Packing List Original ០១ ច្បាប់+ថតចម្លង ០២ ច្បាប់

៣-តារាងលេខបញ្ជិកាឱសថនាំចេញ ០៣ ច្បាប់

-លិខិតអនុញ្ញាតនាំចេញឱសថរបស់ក្រសួងសុខាភិបាលមានសុពលភាពរយៈពេល ០៣ខែ ។

**ប្រការ១០ ៖** ក្រសួងមានសិទ្ធិផ្អាកនូវរាល់ការស្នើសុំនាំចូល និងនាំចេញរបស់គ្រឹះស្ថានអាហារ័ណ នីហារ័ណ និង គ្រឹះស្ថានផលិតឱសថណា ដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ។

**ប្រការ១១ ៖** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១២ ៖** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម៉ម_ប៊ុនហេង

<u>ចម្លងជូនៈ</u>

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជ្រាបជាព័ត៌មាន"
ួងមហាផ្ទៃ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
-ឯកសារ-កាលប្បវត្តិ